ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិ
រៀបចំបុណ្យជាតិ-អន្តរជាតិ
លេខ: ០៩/២០២៥ គ.ជ.ប.អ.

# ផែនការណែនាំ

## ស្តីពី

## ការរៀបចំទិវាសន្តិភាពអន្តរជាតិ លើកទី២៣
## ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៥

**យោង** :-សេចក្តីសម្រេចលេខ ៥៥/២៨២ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០១ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ដែលអំពាវនាវដល់គ្រប់ប្រទេសជាសមាជិកអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ឱ្យប្រារព្ធទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា ជារៀងរាល់ឆ្នាំ ដើម្បីជំរុញការអប់រំ និងបំផុសការយល់ដឹងជាសាធារណៈ អំពីសន្តិភាពក្នុងពិភពលោក ក្នុងតំបន់ និងក្នុងប្រទេសនីមួយៗ ចាត់ទុកថា ថ្ងៃទី២១ ខែកញ្ញា ជាថ្ងៃគ្មានអំពើហិង្សា និងបញ្ឈប់ការផ្ទុះអាវុធនៅទូទាំងប្រទេស

-អនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើត "ទិវាសន្តិភាពអន្តរជាតិ" ដោយកំណត់យកថ្ងៃទី២១ ខែកញ្ញា រៀងរាល់ឆ្នាំដើម្បីប្រារព្ធពិធីនេះនៅទូទាំងប្រទេស ក្នុងគោលបំណងពង្រឹងឧត្តមគតិសន្តិភាពរបស់ប្រជាជាតិ និងប្រជាជនទាំងអស់ក្នុងពិភពលោក សំដៅកាត់បន្ថយភាពតានតឹង ដោយអំពាវនាវឱ្យគ្រប់ប្រជាជាតិ និងប្រជាជនទាំងអស់បញ្ឈប់អំពើហិង្សា និងភាពប្រទូសរ៉ាយ ដែលបង្កឱ្យមានវិវាទ

-សារាចរណែនាំ សម្រាប់អនុវត្តជាអចិន្ត្រៃយ៍លេខ ០៩ សណន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំចាត់តាំងព្រះរាជពិធីបុណ្យទាទសមាស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា បុណ្យជាតិ-បុណ្យអន្តរជាតិ

ដើម្បីរៀបចំទិវាសន្តិភាពអន្តរជាតិ លើកទី២៣ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៥ ឱ្យប្រព្រឹត្តទៅស្របតាមគោលបំណង សំណូមពរនៃអនុក្រឹត្យ សារាចរណែនាំ និងសេចក្តីសម្រេចខាងលើ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សូមធ្វើការណែនាំដូចតទៅ ៖

✳ <u>ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ</u>

ស្រាវជ្រាវចងក្រងខ្លឹមសារ សម្រាប់បម្រើឱ្យការរៀបចំទិវាសន្តិភាពអន្តរជាតិ លើកទី២៣ ដោយរៀបចំសាលិខិតសម្រាប់ជូនថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ ដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយតាមវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន។



វិថីឧកញ៉ា ឈុន កែងវិថីព្រះស៊ីសុវត្ថិ ទល់មុខសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ E-mail: nconif@gmail.com Phone: 012 912 265 / 097 97 69 111

* ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ណែនាំគ្រប់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ រាជធានី ខេត្ត រៀបចំឱ្យមានការសូត្រកំណាព្យ ការប្រគំតន្ត្រីបុរាណ សម័យ ចាប៉ី អាយ៉ៃឆ្លើយឆ្លង ដែលមានខ្លឹមសារពាក់ព័ន្ធទៅនឹងសន្តិភាព នៅតាមទីសាធារណៈ ដើម្បីប្រជាពលរដ្ឋបានចូលរួមកម្សាន្តសប្បាយផង និងទទួលបាននូវខ្លឹមសារ នៃទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា ផង។

* ក្រសួងធម្មការ និងសាសនា

ណែនាំគ្រប់មន្ទីរធម្មការ និងសាសនា រាជធានី ខេត្ត រៀបចំឱ្យមានកម្មវិធីយល់ដឹងអំពីអត្ថន័យទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា តាមរយៈការសូត្រធម៌ សម្តែងធម៌ទេសនា តាមវត្តព្រះពុទ្ធសាសនា និងតាមវិហារសាសនាផ្សេងៗ ដើម្បីផ្សព្វផ្សាយនូវមេត្តាធម៌ ចំពោះមនុស្សសត្វទូទៅ និងសុំសេចក្តីសុខសន្តិភាព សម្រាប់មនុស្សជាតិនៅលើពិភពលោក ព្រមទាំងរម្លឹកគ្រប់វត្តអារាម តុបតែងលម្អ លើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោក និងបំភ្លឺភ្លើងពណ៌អបអរសាទរ។

* ក្រសួងព័ត៌មាន

រៀបចំកម្មវិធីឱ្យបណ្តាញឃោសនា មានវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន សារព័ត៌មានរដ្ឋ និងឯកជនធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ អំពីអត្ថន័យខ្លឹមសារនៃទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា រៀបចំឱ្យមានការជួបសម្ភាសន៍ជាមួយនឹងព្រះសង្ឃ ឥស្សរជនសំខាន់ៗ បញ្ញវន្ត និងនិស្សិត។

* ក្រសួងអប់រំ យុវជន និងកីឡា

បំផុសលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ពន្យល់សិស្ស និស្សិត ឱ្យយល់ដឹងពីការបណ្តុះស្មារតីវប្បធម៌សន្តិភាព នៃទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា នេះជាទិវាគ្មានអំពើហិង្សា និងបញ្ឈប់ការផ្ទុះអាវុធ។

* គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ រោងចក្រ សហគ្រាស អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល

បំផុសមន្ត្រីរាជការ បុគ្គលិក និយោជក និយោជិត កម្មករ យុវជន និងប្រជាពលរដ្ឋ ឱ្យយល់ដឹងអំពីអត្ថន័យទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា ជាទិវាគ្មានអំពើហិង្សា និងបញ្ឈប់ការផ្ទុះអាវុធទូទាំងសកលលោក និងណែនាំឱ្យតុបតែងលម្អលើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោក បំភ្លឺភ្លើងពណ៌តាមក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន អង្គភាព អគារសាធារណៈ ក្រុមហ៊ុន រោងចក្រ សហគ្រាស សាលារៀន តាមសួនច្បារ ទីធ្លាសាធារណៈ។

* ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជួយបង្កលក្ខណៈងាយស្រួលដោះស្រាយសម្ភារៈ ថវិកា ជូនក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលត្រូវចំណាយជាក់ស្តែងចាំបាច់ សម្រាប់បម្រើទិវាដ៏មានសារសំខាន់នេះ ឱ្យបានសមស្រប និងទាន់ពេលវេលា។

* ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ

ជួយណែនាំដល់អង្គភាពក្រោមឱវាទ ឱ្យសហការការពាររក្សាសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម ចរាចរណ៍ បម្រើឱ្យការរៀបចំទិវាសន្តិភាពអន្តរជាតិ ធានាបានសេចក្តីសុខក្សេមក្សាន្ត និងភាពសប្បាយរីករាយជូនប្រជាពលរដ្ឋយើង។

គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សង្ឃឹមនិងជឿជាក់ថា ថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័នលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត នឹងអនុវត្តនូវផែនការណែនាំនេះ ឱ្យសម្រេចបានលទ្ធផលល្អប្រសើរ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥

**គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ**

**ប្រធាន**

**សម្តេចមហាមន្ត្រី គុយ សុផល**

**<u>កន្លែងទទួល</u> ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ
  "ដើម្បីជូនជ្រាប"
- គ្រប់ក្រសួង ស្ថាប័នលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ពាក្យស្លោក

## សម្រាប់ប្រើក្នុងការរៀបចំទិវាសន្តិភាពអន្តរជាតិ លើកទី ២៣

## ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៥

១- ជយោ! ព្រះរាជាណាចក្រកម្ពុជា

២- ជាតិ សាសនា ព្រះមហាក្សត្រ

៣- ជយោ! សន្តិភាព និងអភិវឌ្ឍន៍

៤- មានសន្តិភាព ទើបមានការអភិវឌ្ឍប្រទេសជាតិ

៥- ជយោ! សន្តិភាព និងការបង្រួបបង្រួមជាតិ

៦- ជយោ! សន្តិភាព ដោយនយោបាយ ឈ្នះ ឈ្នះ

៧- ជយោ! នយោបាយ ឈ្នះ ឈ្នះ នាំមកនូវសន្តិភាព

៨- អរគុណសន្តិភាព ក្រោមការដឹកនាំរបស់ **សម្តេចតេជោ ហ៊ុន សែន**

៩- ជយោ! សន្តិភាព ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍

១០- ពង្រឹងឧត្តមគតិសន្តិភាព និងបន្ធូរបន្ថយភាពតានតឹង

១១- ដោះស្រាយរាល់វិវាទ ដោយសន្តិវិធី

១២- បញ្ឈប់រាល់អំពើហិង្សា និងវិវាទនៅលើពិភពលោកទាំងមូល

១៣- ថ្ងៃទី ២១ កញ្ញា ជាថ្ងៃគ្មានអំពើហិង្សា និងបញ្ឈប់ការផ្ទុះអាវុធនៅទូទាំងសកលលោក

១៤- ទិវា ២១ កញ្ញា ជាទិវាអន្តរជាតិសម្រាប់ពលរដ្ឋគ្រប់រូប និងប្រជាជាតិទូទាំងពិភពលោក

១៥- អបអរសាទរយ៉ាងក្លៀវក្លាខួបលើកទី ២៣ ទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា